**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**

លេខ ០៥០/១៧ សជណ

រាជធានីភ្នំពេញ , ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង

-យោងអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៧ ។

រដ្ឋបាលរាជធានីភ្នំពេញ សូមជម្រាបជូនដំណឹងដល់បងប្អូនកម្មករ កម្មការិនីទាំងអស់អោយបានជ្រាបថា ដើម្បីជួយសម្រួលដល់ការចំណាយលើមធ្យោបាយធ្វើដំណើរប្រចាំថ្ងៃ សំដៅលើកកម្ពស់ជីវភាពប្រចាំថ្ងៃរបស់បងប្អូននោះ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** អនុញ្ញាតឱ្យបងប្អូនកម្មករ កម្មការិនីទាំងអស់ ជិះរថយន្តក្រុងគ្រប់ខ្សែរត់ក្នុងរាជធានីភ្នំពេញ របស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង ដោយមិនគិតតម្លៃសេវា ( Free ) រយៈពេល ០២ឆ្នាំ គិតចាប់ពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៧ ដល់ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ ដោយគ្រាន់តែបង្ហាញកាតធ្វើការងារនឹងទទួលបានសេវានេះភ្លាម ។

ទន្ទឹមនឹងនេះ ដើម្បីឆ្លើយតបនឹងសំណូមពរ ក៏ដូចជាសេចក្តីត្រូវការលើសេវាដឹកជញ្ជូនសាធារណៈរថយន្តក្រុង របស់ប្រជាពលរដ្ឋ ព្រះសង្ឃ ចាស់ជរា ជនពិការ កុមារ សិស្ស និស្សិត និងបងប្អូនកម្មករ កម្មការិនីទាំងអស់ រដ្ឋបាលរាជធានីភ្នំពេញនឹងកែសម្រួលគម្រោងផ្លូវ នៃខ្សែរត់ចាស់ ព្រមទាំងដាក់អោយដំណើរការខ្សែរត់ថ្មីរបស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) រាជធានីភ្នំពេញ ដូចខាងក្រោម ៖

**១-ថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០១៧**

ក-<u>ការកែសម្រួលគម្រោងផ្លូវ នៃខ្សែរត់ចាស់</u> :

- **ខ្សែរត់ទី២** : ចេញពីចំណតរថយន្តផ្សារអ៊ីអន២ តាមផ្លូវឧកញ៉ាម៉ុងឬទ្ធី រង្វង់មូលកាំកូស៊ីធី រង្វង់មូលអង់តែនទួលគោក ផ្លូវលេខ៧០ រង្វង់មូលកូចកាណុង ផ្លូវលេខ៤៧ វត្តភ្នំ វិថីព្រះនរោត្តម ស្ពានអាកាសក្បាលថ្នល់ ផ្លូវជាតិលេខ២ ដល់ក្រុងតាខ្មៅ ខេត្តកណ្តាល ។
- **ខ្សែរត់ទី៣** : ចេញពីចំណតសួនច្បារឫស្សីកែវ ផ្លូវជាតិលេខ៥ រង្វង់មូលកូចកាណុង ផ្លូវលេខ៤៧ វត្តភ្នំ វិថីព្រះនរោត្តម ផ្លូវលេខ១៣០ ផ្សារធំថ្មី មហាវិថីកម្ពុជាក្រោម ស្ពានអាកាស៧មករា មហាវិថីសហព័ន្ធរុស្ស៊ី រង្វង់មូលចោមចៅ ផ្លូវជាតិលេខ៣ ដល់ចំណតបុរីសន្តិភាព២ ។

ខ-<u>ដាក់អោយដំណើរការគម្រោងផ្លូវថ្មី</u> :

- **ខ្សែរត់ទី៤A** : ចេញពីចំណតសួនច្បារឫស្សីកែវ ផ្លូវជាតិលេខ៥ រង្វង់មូលកូចកាណុង ផ្លូវលេខ៤៧ វត្តភ្នំ វិថីព្រះនរោត្តម ផ្លូវលេខ១៣០ ផ្សារធំថ្មី វិថីហ្សាដឺហ្គោល ស្តុបនាងគង្ហីង ស្តុបអាងទឹកអូឡាំពិក វិថីព្រះមុនីវង្ស កាត់មុខផ្សារដើមគរ ស្ពានអាកាសស្ទឹងមានជ័យ ផ្លូវវេងស្រេង ស្តុបអាងទឹកកាណាឌីយ៉ា ផ្សារទួលពង្រ ដល់ចំណតបុរីសន្តិភាព២ ។
- **ខ្សែរត់ទី៤B** : ចេញពីចំណតសួនច្បារឫស្សីកែវ ផ្លូវជាតិលេខ៥ រង្វង់មូលកូចកាណុង ផ្លូវលេខ៤៧ វត្តភ្នំ វិថីព្រះនរោត្តម ផ្លូវលេខ១៣០ ផ្សារធំថ្មី វិថីហ្សាដឺហ្គោល ស្តុបនាងគង្ហីង ស្តុបអាងទឹកអូឡាំពិក វិថីព្រះមុនីវង្ស កាត់មុខផ្សារដើមគរ ស្ពានអាកាសស្ទឹងមានជ័យ ផ្លូវវេងស្រេង រង្វង់មូលចោមចៅ ផ្លូវជាតិលេខ៤ ដល់តំបន់សេដ្ឋកិច្ចពិសេស ។

៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

- **ខ្សែរត់ទី៥** : ចេញពីចំណុចផ្សារអ៊ីអន២ តាមផ្លូវលេខ១០០រ៉ា បត់ឆ្វេងតាមផ្លូវលេខ១៩៦៦ ឆ្ពោះទៅផ្លូវលេខ៥៩៨ ផ្លូវលេខ៣៣៧ បត់ស្តាំតាមផ្លូវលេខ៥៦៦ សាលាបឋមសិក្សាពោធិ៍ទូលគោក វិថីតឹមអ៊ុលស៊ុង កាត់ក្រោមស្ពានអាកាស៥មករា មហាវិថីម៉ៅសេទុង ស្តុបប្ញកគោ ស្តុបជលផល វិថីសុធារស ដល់ចំណតផ្សារអ៊ីអន១ ។

**២-ថ្ងៃទី ០១ ខែតុលា ឆ្នាំ២០១៧** :

- **ខ្សែរត់ទី៦** : ចេញពីចំណតផ្សារបុរីរុងរឿង ផ្លូវជាតិលេខ៦ ស្ពានជ្រោយចង្វារ រង្វង់មូលក្បួចកាណុង ផ្លូវលេខ៧០ រង្វង់មូលអង់តែនទូលគោក រង្វង់មូលកាំកូស៊ីធី ផ្លូវឧកញ៉ាម៉ុងឬទ្ធី ផ្លូវសម្តេចជា ស៊ីម បត់ឆ្វេងតាមផ្លូវឧកញ៉ា ទ្រី ហេង ដល់មហាវិថីសហព័ន្ធរុស្ស៊ី បត់ឆ្វេងឆ្ពោះទៅដល់ចំណតផ្សារសេនជូរីផ្លាហ្សា ។
- **ខ្សែរត់ទី៧A** : ចេញពីចំណតគីឡូម៉ែត្រលេខ៩ ផ្លូវជាតិលេខ៥ ផ្លូវលេខ៥៩៨ ស្ពានអាកាស៧មករា ផ្លូវលេខ២៧១ បត់តាមស្ពានអាកាសស្ទឹងមានជ័យ វិថីព្រះមុនីរ៉េត វិថីព្រះសីហនុ វិថីព្រះសុធារស ដល់ចំណតផ្សារអ៊ីអន១ ។
- **ខ្សែរត់ទី៧B** : ចេញពីចំណតគីឡូម៉ែត្រលេខ៩ ផ្លូវជាតិលេខ៥ ផ្លូវលេខ៥៩៨ ស្ពានអាកាស៧មករា ផ្លូវលេខ២៧១ កាត់ស្ពានអាកាសស្ទឹងមានជ័យ ផ្លូវលេខ២៧១ ស្តុបក្បាលថ្នល់ ឆ្លងកាត់ស្ពានព្រះមុនីវង្ស ដល់ចំណតច្បារអំពៅ ។
- **ខ្សែរត់ទី៨** : ចេញពីចំណតគីឡូម៉ែត្រលេខ៩ ផ្លូវជាតិលេខ៥ កាត់ស្ពានព្រែកព្នៅ ផ្លូវឧកញ៉ាលី យ៉ុងផាត់ ផ្លូវជាតិលេខ៦អា ដល់ចំណតផ្សារបុរីរុងរឿង ។

អាស្រ័យហេតុនេះ សូមបងប្អូនប្រជាពលរដ្ឋ ព្រះសង្ឃ ចាស់ជរា ជនពិការ កុមារ សិស្ស និស្សិត និងបងប្អូនកម្មករ កម្មការិនីទាំងអស់ជ្រាប និងចូលរួមជិះរថយន្តក្រុងរបស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) រាជធានីភ្នំពេញ នៃរដ្ឋបាលរាជធានីភ្នំពេញ ប្រកបដោយសុវត្ថិភាព និងផាសុកភាព ។

ទទួលបានសេចក្តីជូនដំណឹងនេះ រដ្ឋបាលខណ្ឌទាំង១២ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង និងមន្ទីរ អង្គភាពពាក់ព័ន្ធត្រូវអនុវត្តសេចក្តីជូនដំណឹងនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

**<u>កន្លែងទទួល</u>:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
"ដើម្បីជូនជ្រាប"
-គ្រប់ស្ថានីយ៍វិទ្យុ ទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយ
"ដើម្បីជួយផ្សព្វផ្សាយ"
-ឯកសារ-កាលប្បវត្តិ